# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 10-Jul-2019, 12:05
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**:

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

## សំណើរបស់មេធាវីការពារក្ដីលោក ខៀវ សំផន សុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រនៃសារណាបណ្ដឹងសាទុក្ខ

---

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

ដាក់ជូន៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Florence Ndepele Mwachande MUMBA

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Cécile ROUBEIX

កញ្ញា Dounia HATTABI

លោក Stéphane NICOLAÏ

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Phillip RAPOZA

ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**មេធាវីការពារក្តីលោក នួន ជា**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") បានប្រកាសនៅក្នុងសវនាការជាសាធារណៈថា លោក ខៀវ សំផន ជាប់ពិរុទ្ធពីបទប្រល័យពូជសាសន៍ (លើជនជាតិវៀតណាម) បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងបទរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ហើយបានផ្តន្ទាទោសលោក ខៀវ សំផន ឲ្យជាប់ពន្ធនាគារអស់មួយជីវិត[1]។ អង្គជំនុំជម្រះបានបញ្ជាក់ថា នឹងជូនដំណឹងអំពីសំអាងហេតុពេញលេញនៃសាលក្រមជាលាយលក្ខណ៍អក្សរ "ក្នុងពេលសមស្រប"[2]។

២. នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ មេធាវីការពារក្តីលោក ខៀវ សំផន ("មេធាវីការពារក្តី") បានធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ហើយបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូល ("តុលាការកំពូល") ឲ្យធ្វើមោឃភាពសាលក្រម ដោយមូលហេតុវិការៈទម្រង់ និងគ្មានសំអាងហេតុ[3]។ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ តុលាការកំពូលបានសម្រេចមិនទទួលយកបណ្តឹងសាទុក្ខនេះ[4]។

៣. នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ មេធាវីការពារក្តីបានស្នើសុំធ្វើមោឃភាពសេចក្តីសម្រេចនេះ ដោយហេតុថា ក្រុមប្រឹក្សាចៅក្រម ដែលបានចេញសេចក្តីសម្រេចនៅពេលនោះ មានសមាសភាពមិនត្រឹមត្រូវតាមកំណត់ច្បាប់[5]។ អស់រយៈពេលជាងបីខែក្រោយមក គឺនៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩ ទើបតុលាការកំពូលបានជូនដំណឹងអំពីសំណើនេះ[6]។

---

[1] ប្រតិចារឹកសវនាការ ("ប្រតិចារឹក") ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E1/529.1 ទំព័រ ៣៨-៤២ ចន្លោះពីម៉ោង ១១:២៨ ដល់ម៉ោង ១១:៣៨។

[2] ប្រតិចារឹក ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E1/529.1 ទំព័រ ៣ ប្រហែលម៉ោង ៩:៣៦។

[3] បណ្តឹងសាទុក្ខភ្លាមៗរបស់លោក ខៀវ សំផន ប្រឆាំងនឹងសាលក្រម ប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E463/1។

[4] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងការប្រកាសសេចក្តីសង្ខេបនៃសាលក្រមដែលបានធ្វើឡើងនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ឯកសារ E463/1/3។ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩ មេធាវីការពារក្តីបានស្នើសុំឲ្យបកប្រែសេចក្តីសម្រេចជាភាសាបារាំង ដែលត្រូវបានជូនដំណឹងនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩។

[5] សំណើរបស់លោក ខៀវ សំផន សុំធ្វើមោឃភាពសេចក្តីសម្រេច E463/1/3 ទាក់ទងនឹងបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹង សាលក្រមប្រកាសថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ ឯកសារ E463/1/4។

[6] សំណើនេះត្រូវបានដាក់នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង ១១ និង ៥២ នាទី ប៉ុន្តែ ទើបតែត្រូវបានជូនដំណឹង នៅថ្ងៃទី

៤. នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ ភាគីបានទទួលសេចក្តីជូនដំណឹងអំពីសំអាងហេតុពេញលេញនៃសាលក្រមលើសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ កម្រាស់ ៤.១០១ ទំព័រ ជាភាសាខ្មែរ ២.៨២៨ ទំព័រ ជាភាសាបារាំង ២.៣៨៧ ទំព័រ ជាភាសាអង់គ្លេស (រួមទាំងឧបសម្ព័ន្ធ) និងកំណត់សម្គាល់ជើងទំព័រចំនួន ១៤.៤៤៦ ("សាលក្រមជាលាយលក្ខណ៍អក្សរ")[7]។

៥. នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ មេធាវីការពារក្តីបានស្នើសុំរយៈពេល ៨ ខែ និងកម្រាស់ ១០០ ទំព័រ សម្រាប់ការដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ជាពីរភាសា ចំណែកឯមេធាវីការពារក្តីលោក នួន ជា បានស្នើសុំរយៈពេល ៦ ខែ និងកម្រាស់ ១០០ ទំព័រ សម្រាប់ការដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ[8]។ នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ តុលាការកំពូលបានផ្តល់ជូនភាគីទាំងអស់នូវរយៈពេល ៣ ខែ និងកម្រាស់ ៦០ ទំព័រ[9]។

៦. នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ មេធាវីការពារក្តីបានស្នើសុំឱ្យពិនិត្យឡើងវិញលើសេចក្តីសម្រេចនេះ ដោយហេតុថា សេចក្តីសម្រេចនេះមានកំហុសឆ្គង និងមានឥទ្ធិពលធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់លោក ខៀវ សំផន ក្នុងការទទួលបានពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន ព្រមទាំងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សមភាពនៃមធ្យោបាយតទល់ក្តី[10]។ ជាងមួយខែក្រោយមក គឺនៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩ តុលាការកំពូលបានបដិសេធសំណើនេះ[11]។

---

០៣ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង ១០ និង ២៨ នាទី។

[7] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** ("សាលក្រមជាលាយលក្ខណ៍អក្សរ)។

[8] សំណើរបស់លោក ខៀវ សំផន សុំពន្យារពេល និងបន្ថែមចំនួនទំព័រនៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ ឯកសារ **F39/1.1** ("សំណើ **F39/1.1**"), សំណើបន្ទាន់លើកទីមួយរបស់ នួន ជា សុំចំនួនទំព័រ និងពេលវេលាបន្ថែមសម្រាប់ការដាក់ជូនសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ ឯកសារ **F40/1.1**។

[9] សេចក្តីសម្រេចលើសំណើរបស់ នួន ជា និង ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រ សម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ ឯកសារ **F43**។

[10] សំណើរបស់លោក ខៀវ សំផន សុំឱ្យពិនិត្យឡើងវិញលើសេចក្តីសម្រេចស្តីពីការសុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ ឯកសារ **F44** ("សំណើ **F44**")។

[11] សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំឱ្យពិចារណាឡើងវិញនូវសេចក្តីសម្រេចអំពីការស្នើសុំបន្ថែមពេលវេលា និងចំនួនទំព័រ លើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ **F44/1** ("សេចក្តីសម្រេច **F44/1**")។

៧. នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដោយបានលើកឡើងនូវកំហុសតែមួយគត់របស់អង្គជំនុំជម្រះ[12]។

៨. នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ មេធាវីការពារក្តីលោក នួន ជា បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដោយបានប្រកាសអំពីមូលដ្ឋានបណ្តឹងសាទុក្ខចំនួន ៣៥១[13]។

៩. នៅថ្ងៃដដែលនោះ មេធាវីការពារក្តីបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ហើយក្នុងលក្ខខណ្ឌមិនសមស្របនឹងការជំនុំជម្រះក្តីដោយយុត្តិធម៌ និងហួសពីលទ្ធភាពមនុស្ស មេធាវីការពារក្តីបានរកឃើញកំហុសរបស់អង្គជំនុំជម្រះយ៉ាងហោចណាស់ចំនួន ១.៨២៤ និងសេចក្តីសម្រេចចំនួន ៣៥៥ ដែលត្រូវប្តឹងសាទុក្ខ ក្នុងពេលដំណាលគ្នានឹងសាលក្រមលើអង្គសេចក្តី[14]។

១០. តាមរយៈសំណើនេះ មេធាវីការពារក្តីស្នើសុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រនៃសារណាបណ្តឹងសាទុក្ខ (ផ្នែកទី I)។ មេធាវីការពារក្តីក៏ស្នើសុំបន្ថែមពេលវេលា សម្រាប់ការដាក់ចម្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា (ផ្នែកទី II)។ មេធាវីការពារក្តីក៏ស្នើសុំផងដែរឱ្យតុលាការកំពូលគ្រោងបើកកិច្ចប្រជុំរៀបចំសវនាការ ជាសាធារណៈ (ផ្នែកទី III)។

## I. <u>ការបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រ</u>

### ១. <u>ច្បាប់ជាធរមាន</u>

---

[12] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ **E465/2/1**។

[13] សេចក្តីជូនដំណឹងរបស់ នួន ជា អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ **E465/3/1**។

[14] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ **E465/4/1**។

១១. វិធាន ១០៧(៤) នៃវិធានផ្ទៃក្នុង ចែងថា ម្ចាស់បណ្តឹងសាទុក្ខត្រូវដាក់សារណាបណ្តឹងសាទុក្ខ ក្នុងរយៈពេល ៦០ ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងអំពីការប្តឹងសាទុក្ខ។ មាត្រា ៥.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ នៅ អ.វ.ត.ក (“សេចក្តីណែនាំអនុវត្ត”) ចែងថា ឯកសារដាក់នៅតុលាការកំពូលនៃ អ.វ.ត.ក “មិនត្រូវលើសពី ៣០ ទំព័រ ជាភាសាអង់គ្លេស ឬបារាំង ឬ ៦០ ទំព័រ ជាភាសាខ្មែរ”។

១២. យោងតាមវិធាន ៣៩(២) នៃវិធានផ្ទៃក្នុង “ចៅក្រមអាចកំណត់ពេលវេលា សម្រាប់ដាក់សារណា សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងឯកសារពាក់ព័ន្ធទៅនឹងសំណើសុំណាមួយ ឬបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខ ដោយគិតពិចារណាដល់កាលៈទេសៈនៃរឿងក្តីនោះ”។ យោងតាមវិធាន ៣៩(៤) “តាមរយៈពាក្យសុំរបស់ភាគីពាក់ព័ន្ធ ឬតាមគំនិតផ្តួចផ្តើមរបស់ខ្លួន [...] អង្គជំនុំជម្រះអាច៖ ក- ពន្យារពេលវេលាកំណត់ ដែលខ្លួនបានកំណត់ ខ- ទទួលស្គាល់ថាមានសុពលភាពចំពោះកិច្ចទាំងឡាយណាដែលបានធ្វើក្រោយពីពេលកំណត់ដែលមានចែងក្នុងវិធានផ្ទៃក្នុងនេះ ត្រូវបានផុតរលត់ ប្រសិនបើខ្លួនយល់ឃើញថាត្រឹមត្រូវសមហេតុផល”។ មាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្តបញ្ជាក់ថា “អង្គជំនុំជម្រះដែលពាក់ព័ន្ធ អាចបង្កើនចំនួនសន្លឹករបស់ឯកសារ នៅក្នុងកាលៈទេសៈពិសេស” តាមការស្នើសុំរបស់ភាគីណាមួយ។

## ២. ភាពចាំបាច់ក្នុងការបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រ

១៣. រយៈពេល ៦០ ថ្ងៃ និងចំនួនកំណត់ ៣០ ទំព័រ ដែលចែងដោយវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តមិនសមស្រប និងមិនគ្រប់គ្រាន់ទាល់តែសោះ នៅក្នុងរឿងក្តីនេះ។ ការកម្រិតនេះមិនអាចឲ្យមេធាវីការពារក្តីដាក់ “សារណាបណ្តឹងសាទុក្ខ ដោយបញ្ជាក់ពីទឡ្ហីករណ៍ និងឯកសារសំអាងផ្លូវច្បាប់ដែលគាំទ្រមូលដ្ឋាននីមួយៗ” ក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ តាមការកំណត់របស់វិធាន ១០៥(៣) នៃវិធានផ្ទៃក្នុង បានទេ។

១៤. ករណីនេះធ្លាប់បានកើតឡើងម្តងរួចមកហើយ ក្នុងសំណុំរឿង ០០២/០១ ពេលមេធាវីការពារក្តីប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមដែលមានកម្រាស់ ១.១០៦ ទំព័រ ជាភាសាខ្មែរ ៨៥៤ ជាភាសាបារាំង និង ៦៩៥ ជាភាសាអង់គ្លេស (រួមទាំងឧបសម្ព័ន្ធ)។ នៅពេលនោះ តុលាការកំពូលបានអនុញ្ញាតឲ្យមេធាវីការពារក្តីទាំងពីរក្រុមដាក់សារណាបណ្តឹងសាទុក្ខ កម្រាស់ ២១០ ទំព័រ ក្នុងរយៈពេល ៣ ខែ

តែមួយភាសាជាមុនសិន ក្រោយការដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ[15]។ តុលាការកំពូលបានពិចារណាលើ "ទំហំ និងភាពស្មុគស្មាញនៃសំណុំរឿង និងសាលក្រម" និងការដែលសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខអាចបង្ហាញឲ្យឃើញថា បណ្តឹងសាទុក្ខនឹងមាន "លក្ខណៈទូលំទូលាយ" ដែលតម្រូវឲ្យម្ចាស់បណ្តឹងសាទុក្ខមាន "ពេលវេលា និងចំនួនទំព័រគ្រប់គ្រាន់" សម្រាប់ "ការលើកឡើងប្រកបដោយអត្ថន័យ"[16]។ តុលាការកំពូលក៏បានរម្លឹកផងដែរថា ការបន្ថែមពេលវេលា និងការបង្កើនចំនួនទំព័រ ត្រូវសមាមាត្រទៅនឹងទំហំនៃបណ្តឹងសាទុក្ខ[17] ព្រមទាំងបានរម្លឹកអំពីភាពខុសគ្នារវាងនីតិវិធីបណ្តឹងសាទុក្ខនៅចំពោះមុខ អ.វ.ត.ក និងនីតិវិធីបណ្តឹងសាទុក្ខនៅចំពោះមុខតុលាការអន្តរជាតិផ្សេងទៀត[18]។

១៥. សំណុំរឿង ០០២/០២ និងសាលក្រមជាលាយលក្ខណ៍អក្សរ មានទំហំធំ និងភាពស្មុគស្មាញខ្លាំងលើសសំណុំរឿង ០០២/០១។ តាមភាពសមហេតុផល សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន លើសំណុំរឿង ០០២/០២ បង្ហាញឲ្យឃើញបណ្តឹងសាទុក្ខមួយដែលមានទំហំធំជាងសំណុំរឿង ០០២/០១។

១៦. មេធាវីការពារក្តីបានបង្ហាញយ៉ាងវែង និងច្បាស់ អំពីលក្ខណៈពិសេសនៃសំណុំរឿង ០០២/០២ នៅក្នុងសារណាមុនៗរបស់ខ្លួន។ ដើម្បីកុំឲ្យមានភាពច្រំដែល មេធាវីការពារក្តីសូមយោងទៅឯកសារទាំងនោះ[19]។ មេធាវីការពារក្តីគ្រាន់តែសូមរម្លឹកនៅទីនេះថា សាលក្រមសំណុំរឿង ០០២/០២ មានកម្រាស់លើសសំណុំរឿង ០០២/០១ ដល់ទៅ ៣,៥ ដង មានកំណត់សម្គាល់ជើងទំព័រលើសសំណុំរឿង ០០២/០១ ដល់ទៅ ៤,៤ ដង មានសំណុំអង្គហេតុដែលត្រូវពិនិត្យលើសសំណុំរឿង ០០២/០១ ជិត ៤ ដង មានការផ្តន្ទាទោសលោក ខៀវ សំផន លើសសំណុំរឿង ០០២/០១ ដល់ទៅ ៦ ដង

---

[15] សេចក្តីសម្រេចលើសំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រ សម្រាប់សារណាបណ្តឹងសាទុក្ខ និងសារណាតប ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ឯកសារ **F9** ("សេចក្តីសម្រេច **F9**")។

[16] សេចក្តីសម្រេច **F9** កថាខណ្ឌ ១៣។

[17] សេចក្តីសម្រេច **F9** កថាខណ្ឌ ១៤។

[18] សេចក្តីសម្រេច **F9** កថាខណ្ឌ ១៦ និងកថាខណ្ឌ ១៨។

[19] សំណើ **F39/1.1** កថាខណ្ឌ ១៧ ដល់កថាខណ្ឌ ២៣, ការឆ្លើយតប និងចម្លើយតបរបស់លោក ខៀវ សំផន ទៅនឹងសហព្រះរាជអាជ្ញា ស្តីពីការបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រ នៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ ឯកសារ **F41/1** កថាខណ្ឌ ១១ និងកថាខណ្ឌ ១៣។

ហើយបញ្ហាគតិយុត្តិមិនត្រឹមតែមានលក្ខណៈស្មុគស្មាញខ្លាំងនោះទេ ថែមទាំងប្លែកខុសគេទៀតផង (ធៀបនឹងសំណុំរឿង ០០២/០១ ក៏ដូចជាធៀបនឹងតុលាការអន្តរជាតិផ្សេងទៀត)។

១៧. មេធាវីការពារក្តីសូមរម្លឹកថែមទៀតថា ខុសពីសំណុំរឿង ០០២/០១ ភ័ស្តុតាងថ្មីៗជាច្រើនត្រូវបានទទួលយក ក្នុងពេលជំនុំជម្រះក្តីសំណុំរឿង ០០២/០២ (រហូតដល់ចប់សវនាការលើអង្គសេចក្តី) ហើយទោះបីជាធ្លាប់ទទួលបានមធ្យោបាយបន្ថែមក្នុងពេលជំនុំជម្រះក្តីក៏ដោយ ក៏ឥឡូវនេះ មេធាវីការពារក្តីមិនទទួលបានអ្វីទាំងអស់ ទោះបីជាខ្លួនបានដាក់សំណើជាមុនទៅកាន់ការិយាល័យរដ្ឋបាល ដើម្បីកាត់បន្ថយផលប៉ះពាល់លើរយៈពេលប្តឹងសាទុក្ខក៏ដោយ[20]។

១៨. សូមបន្ថែមថា មេធាវីការពារក្តីខ្វះពេលវេលាខ្លាំងបំផុត ក្នុងការរៀបចំសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខលើសំណុំរឿង ០០២/០២។ ជាពិសេស មេធាវីការពារក្តីមិនអាចផ្ទៀងផ្ទាត់តាមការគួរនូវប្រភពអង្គច្បាប់ និងអង្គហេតុ ដែលអង្គជំនុំជម្រះយកមកធ្វើជាមូលដ្ឋានគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់ខ្លួនបានឡើយ។ ផ្ទុយទៅវិញ សិទ្ធិប្តឹងសាទុក្ខរបស់ជនដែលជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ដែលធានាដោយមាត្រា ១៤.៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គឺសិទ្ធិ “សុំឲ្យពិនិត្យលើការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោសឡើងវិញ ដោយផ្ទៀងផ្ទាត់ថាតើមានភ័ស្តុតាងគ្រប់គ្រាន់ដែរឬទេ និងដោយផ្អែកលើបទប្បញ្ញត្តិច្បាប់ជាធរមាន”[21]។ មេធាវីការពារក្តីត្រូវតែអាចធានាបានថា ខ្លួនមិនខ្វះមូលដ្ឋានបណ្តឹងសាទុក្ខ។ ម្យ៉ាងវិញទៀត មេធាវីការពារក្តីមិនអាចរៀបចំកំហុសដែលបានស្រង់ឡើង ក្នុងឯកសារមួយដែលអាចធ្វើជាប្លង់ សម្រាប់សារណាបណ្តឹងសាទុក្ខរបស់ខ្លួនបានឡើយ ហើយត្រូវបង្ខំចិត្តបញ្ជាក់អំពីកំហុសទាំងនេះ ដោយសង្ខេប។ ក៏ប៉ុន្តែកំហុសដែលបានរកឃើញ នៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ទាមទារយ៉ាងហោចណាស់ឲ្យមានច្រើនកថាខណ្ឌ និងជារឿយៗ ច្រើនទំព័រ ដើម្បីពង្រីកន័យសេចក្តីឲ្យបានក្បោះក្បាយក្នុងសារណា។ លើសពីនេះទៀត មេធាវីការពារក្តីត្រូវដាក់បញ្ចូលបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចបន្ទាន់បង្ខំផងដែរ។

---

[20] សំណើ **F39/1.1** កថាខណ្ឌ ២៨ ដល់កថាខណ្ឌ ៣៥។

[21] រឿងក្តី *Bandajevsky ទល់នឹងប្រទេសបេឡារុស* ឯកសារលេខ ១១០០/២០០២ ការកត់សម្គាល់របស់គណៈកម្មាធិការសិទ្ធិមនុស្ស នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ១០.១៣។

១៩. ដើម្បីបំពេញការងារចាំបាច់ ដែលខ្លួនមិនអាចធ្វើបាន ក្នុងពេលរៀបចំសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងដើម្បីបង្ហាញសំអាងហេតុជាច្រើន មេធាវីការពារក្តីស្នើសុំដាក់សារណាបណ្តឹងសាទុក្ខកម្រាស់ **៩៥០ ទំព័រ** ជាភាសាបារាំង ក្នុងរយៈពេល **១០,៥ ខែ** គិតចាប់ពីពេលដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងដាក់សំណៅបកប្រែជាភាសាខ្មែរតាមក្រោយឲ្យបានឆាប់បំផុត។ ដូចក្នុងសំណុំរឿង ០០២/០១ ដែរ មេធាវីការពារក្តីត្រូវអាចដាក់សារណាបណ្តឹងសាទុក្ខ **តែមួយភាសាជាមុនសិន**។ ខុសពីភាគីផ្សេងទៀត មេធាវីការពារក្តីពុំមានធនធានបកប្រែផ្ទៃក្នុងទេ។ មុខតំណែងអ្នកបកប្រែបារាំង/ខ្មែរ នៅក្នុងអង្គភាពគាំពារការការពារក្តី ត្រូវបានលុបចោល នៅចុងឆ្នាំ២០១៨ ហើយធនធានរបស់អង្គភាពបកប្រែភាសាថយចុះជាងមុនយ៉ាងខ្លាំង។ លើសពីនេះទៅទៀត មេធាវីការពារក្តីសូមសង្កត់ធ្ងន់ថា វាជារឿងខាតពេលច្រើន សម្រាប់មេធាវីការពារក្តី និងអង្គភាពបកប្រែភាសា ក្នុងការបកប្រែជាបណ្តើរៗនូវឯកសារមួយដែលមានការកែប្រែជាប្រចាំ[22]។

២០. សំណើសុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រ មានភាពសមហេតុសមផល**បំផុត** ពីព្រោះនេះគឺជា**លក្ខខណ្ឌអប្បបរមាចាំបាច់**ដែលមេធាវីការពារក្តីត្រូវទទួលបាន ដោយពិចារណាទៅលើទំហំនៃសំណុំរឿង ០០២/០២ ធៀបនឹងសំណុំរឿង ០០២/០១ ដូចបានរម្លឹកខាងលើ[23]។ ប្រសិនបើពុំមានពេលវេលា និងមធ្យោបាយអប្បបរមាចាំបាច់នេះទេ បណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន មិនអាចត្រូវបានលើកឡើងឲ្យបានត្រឹមត្រូវនោះទេ។

## ៣. <u>"ភាពឆាប់រហ័ស" នៃនីតិវិធីបណ្តឹងសាទុក្ខលើសំណុំរឿង ០០២/០២ និងសិទ្ធិធ្វើបណ្តឹងសាទុក្ខពិតប្រាកដ និងប្រកបដោយប្រសិទ្ធភាព</u>

២១. មេធាវីការពារក្តីបានកត់សម្គាល់យ៉ាងច្បាស់ថា ទន្ទឹមនឹងការបដិសេធសំណើសុំឲ្យពិនិត្យឡើងវិញ តុលាការកំពូលបានប្រកាសថា "ការរៀបចំសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ គឺជានីតិវិធីមួយក្នុងគោលបំណងកម្រិតអំពីពេលវេលា និងខ្លឹមសារ បើធៀបនឹងការរៀបចំ និងការដាក់សារណានៃប

[22] សំណើ **F39/1.1** កថាខណ្ឌ ២៥។ លើសពីនេះទៀត ផ្ទុយពីការប្រកាសរបស់តុលាការកំពូល ពុំមានការអនុវត្តណាមួយ នៅចំពោះមុខ អ.វ.ត.ក ដែលថា ឯកសារធំៗត្រូវបានបញ្ជូនទៅបកប្រែជាបណ្តើរៗនោះទេ។ តាមពិត ឯកសារទាំងនេះត្រូវបានដាក់សិន រួចទើបបកប្រែ។ សូមមើលសំណើ **F44** កថាខណ្ឌ ៧ និងកំណត់សម្គាល់ជើងទំព័រលេខ ១៥ ដល់លេខ ១៧។

[23] សូមមើលខាងលើ កថាខណ្ឌ ១៤ ដល់កថាខណ្ឌ ១៧។

ណ្ដឹងសាទុក្ខដែលមានសំអាងហេតុពេញលេញ”[24]។ តុលាការកំពូលបានបន្ថែមទៀតថា ពុំមានការហាមឃាត់ដាច់ខាតណាមួយលើការកែប្រែមូលដ្ឋានបណ្ដឹងសាទុក្ខ ក្រោយពីការដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខឡើយ[25]។ តុលាការកំពូលក៏បានចង្អុលបង្ហាញផងដែរថា សេចក្ដីសម្រេចដំបូងរបស់ខ្លួនលើសំណើសុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រ ត្រូវបានចេញ “ដោយពុំបានប៉ះពាល់ដល់សំណើនាពេលអនាគតដែលសុំបន្ថែមពេលវេលា ឬចំនួនទំព័រលើសារណាបណ្ដឹងសាទុក្ខឡើយ”[26]។

២២. ទោះជាយ៉ាងនេះក្ដី ខណៈមិនរំពឹងថាមានលក្ខខណ្ឌរឹតត្បិតដល់សិទ្ធិរបស់មេធាវីការពារក្ដីដល់ថ្នាក់នេះ នៅក្នុងក្របខ័ណ្ឌនៃបណ្ដឹងសាទុក្ខ មេធាវីការពារក្ដីព្រួយបារម្ភថា តុលាការកំពូលមិនអនុញ្ញាតឲ្យខ្លួនធ្វើការងារឲ្យបានត្រឹមត្រូវ សូម្បីតែនៅក្នុងដំណាក់កាលរៀបចំសារណាបណ្ដឹងសាទុក្ខ។

២៣. ជាក់ស្ដែង យោងតាមសេចក្ដីសម្រេចថ្មីៗចុងក្រោយនេះរបស់តុលាការកំពូល មេធាវីការពារក្ដីមានអារម្មណ៍ប្រាកដក្នុងចិត្តថា តុលាការកំពូលនឹងមិនខ្វល់អំពីតម្រូវការចាំបាច់ និងសិទ្ធិរបស់មេធាវីការពារក្ដីឡើយ គឺគិតតែពីផ្ដល់អាទិភាពដល់ “ភាពចាំបាច់ក្នុងការធានាឲ្យបាននូវកិច្ចដំណើរការនីតិវិធី*ឆាប់រហ័ស* ស្របតាមក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក និងបទដ្ឋានអន្តរជាតិ”[27]។

២៤. ប៉ុន្តែ ក្នុងក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក និងបទដ្ឋានអន្តរជាតិ ពុំមានចែងអំពី “ភាពឆាប់រហ័ស” នៃកិច្ចដំណើរការនីតិវិធីនោះទេ។ ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ចែងថា អង្គជំនុំជម្រះ “ត្រូវប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវ និងឆាប់រហ័ស (...) ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ” ហើយត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនឲ្យស្របតាមកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[28]។ កតិកាសញ្ញានេះធានាដល់ជនជាប់ចោទនូវសិទ្ធិក្នុងការទទួលបានការជំនុំ

---

[24] សេចក្ដីសម្រេច F44/1 ទំព័រ ៤-៥។

[25] សេចក្ដីសម្រេច F44/1 ទំព័រ ៥។

[26] សេចក្ដីសម្រេច F44/1 ទំព័រ ៥។

[27] សេចក្ដីសម្រេច F44/1 ទំព័រ ៤ (យើងខ្ញុំជាអ្នកដាក់អក្សរទ្រេត)។

[28] មាត្រា ៣៣ ថ្មី (វាក្យខណ្ឌ ១ និងវាក្យខណ្ឌ ២) និងមាត្រា ៣៧ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក។ សូមមើលផងដែរ វិធាន ២១(១) នៃវិធានផ្ទៃក្នុង។

ជម្រះ "ដោយឥតពន្យារពេលយូរហួស"[29] នៅពីក្រោមសិទ្ធិក្នុងការទទួលបានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួន[30]។

២៥. ដូច្នេះ ទោះជាក្នុងករណីណាក៏ដោយ ការព្រួយបារម្ភពាក់ព័ន្ធនឹង "ភាពឆាប់រហ័ស" នៃកិច្ចដំណើរការនីតិវិធី មិនត្រូវដកហូតពីជនជាប់ចោទនូវសិទ្ធិ ដូចបានធានាដោយបទដ្ឋានអន្តរជាតិ និងក្នុងក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក ឡើយ។ សិទ្ធិក្នុងការទទួលបានការជំនុំជម្រះឆាប់រហ័សមិនស្ថិតនៅក្នុងនេះទេ។ សិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយឥតពន្យារពេលក៏មិនរាប់បញ្ចូលដែរ។

២៦. មេធាវីការពារក្តីសូមសង្កត់ធ្ងន់ថា លោក ខៀវ សំផន ជាអ្នកពាក់ព័ន្ធមុនគេនឹងរយៈពេលនៃកិច្ចដំណើរការនីតិវិធី។ គាត់គ្មានប្រយោជន៍អ្វីទៅអូសបន្លាយពេលពេលវេលាទេ ផ្ទុយទៅវិញ គាត់រឹតតែចង់ឲ្យកិច្ចដំណើរការនីតិវិធីប្រព្រឹត្តទៅបានឆាប់រហ័សថែមទៀត។

២៧. លោក ខៀវ សំផន មិនមែនជាអ្នកទទួលខុសត្រូវ ចំពោះការឃុំឃាំង និងការចោទប្រកាន់ នៅឆ្នាំ ២០០៧ ក្នុងអាយុ ៧៦ ឆ្នាំ និងទើបអាចប្តឹងសាទុក្ខបាន នៅឆ្នាំ២០១៩ ក្នុងអាយុ ៨៨ ឆ្នាំ ទេ។ គាត់មិនមែនជាអ្នកទទួលខុសត្រូវ ចំពោះវិសាលភាពនៃដីកាបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ចំពោះការស៊ើបអង្កេតតាមផ្លូវតុលាការរាប់ឆ្នាំ ចំពោះសេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ និងចំពោះការរៀបចំការជំនុំជម្រះក្តីពីរដងលើរូបគាត់អស់រយៈពេលជាច្រើនឆ្នាំនោះទេ។ គាត់ក៏មិនមែនជាអ្នកទទួលខុសត្រូវ ចំពោះការដាក់បញ្ចូលភស្តុតាងថ្មីយ៉ាងច្រើនសន្ធឹកសន្ធាប់ ក្នុងពេលជំនុំជម្រះក្តីលើសំណុំរឿង ០០២/០២ ហើយគាត់ក៏មិនមែនជាអ្នកទទួលខុសត្រូវ ចំពោះពេលវេលាដែលអង្គជំនុំជម្រះបានចំណាយលើការតាក់តែងសំអាងហេតុនៃសាលក្រមរាប់ពាន់ទំព័រនោះដែរ។

២៨. ថ្ងៃនេះ លោក ខៀវ សំផន មិនស្នើសុំអ្វីច្រើនទេ គឺត្រឹមតែអ្វីដែលចាំបាច់ប៉ុណ្ណោះ ដើម្បីទទួលបានសិទ្ធិធ្វើបណ្តឹងសាទុក្ខពិតប្រាកដ និងប្រកបដោយប្រសិទ្ធភាព ប្រឆាំងនឹងការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរលើរូបគាត់។

---

[29] មាត្រា ១៤(៣)(គ)។

[30] មាត្រា ១៤(៣)(ខ)។

២៩. មិនមែនដោយសារតែតុលាការជួបប្រទះបញ្ហាហិរញ្ញវត្ថុ ទើបធ្វើឲ្យបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន ក្នុងសំណុំរឿង ០០២/០២ ត្រូវតែ "ឆាប់រហ័ស" ឬឥតពន្យារពេលនោះទេ។ តុលាការកំពូលបានបញ្ជាក់ថា "ប្រសិនបើពុំមានថវិកាគ្រប់គ្រាន់ក្នុងការធានានូវការជំនុំជម្រះដែលច្បាប់បានតម្រូវនោះទេ រាល់កិច្ចដំណើរការនីតិវិធីនៃ អ.វ.ត.ក ត្រូវតែបញ្ចប់ ហើយតុលាការត្រូវបិទទ្វារ"[31]។

៣០. ក្រៅពីនេះទៀត មិនមែនដោយសារតែលោក ខៀវ សំផន មានវ័យចាស់ជរា និង/ឬដោយសារតែគាត់ត្រូវបានផ្តន្ទាទោសម្តងរួចហើយ នៅក្នុងសំណុំរឿង ០០២/០១ ទើបបណ្តឹងសាទុក្ខរបស់គាត់នៅក្នុងសំណុំរឿង ០០២/០២ ត្រូវតែដាក់ឲ្យបាន "ឆាប់រហ័ស" ឬដោយឥតពន្យារពេលនោះទេ។ ប្រសិនបើការរៀបចំការជំនុំជម្រះក្តីលើកទីពីរ គ្រាន់តែមានគោលបំណងផ្តល់យុត្តិធម៌បង្គ្រប់កិច្ច គ្មានអ្វីត្រូវទើសទាល់នោះទេ។

៣១. លោក ខៀវ សំផន និងមេធាវីការពារក្តី សុទ្ធតែជាមនុស្ស។ លោក ខៀវ សំផន នៅតែត្រូវបានសន្មតថាគ្មានទោសនៅក្នុងសំណុំរឿង ០០២/០២។ មេធាវីមិនមែនការពារក្តីឲ្យគាត់គ្រាន់តែ ដើម្បីបង្គ្រប់កិច្ចនោះទេ។ ប្រសិនបើមេធាវីការពារក្តីមិនទម្លាប់នឹងពេលវេលាខ្លី ខ្លួនមិនអាចទ្រាំទ្រនឹងកាលកំណត់មិនសមរម្យសម្រាប់ការដាក់សេចក្តីជូនដំណឹងអំពីសាទុក្ខ ជាមួយនឹងមធ្យោបាយដែលមាននោះបានទេ។ មេធាវីការពារក្តីត្រូវការពេលវេលាសមស្រប សម្រាប់សរសេរសារណាបណ្តឹងសាទុក្ខ។ ម្យ៉ាងវិញទៀត លោក ខៀវ សំផន មានសិទ្ធិតាមដាន និងរួមចំណែកដល់ការការពារខ្លួនរបស់គាត់ ដោយគិតគូរដល់វ័យចាស់ជរា និងការលំបាកពាក់ព័ន្ធ[32]។

## II. <u>ចម្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា</u>

---

[31] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ឯកសារ **E284/4/8** កថាខណ្ឌ ៧៥។

[32] លិខិតប្រគល់សិទ្ធិធ្វើបណ្តឹងសាទុក្ខ (វិធាន១០៦(៣) នៃវិធានផ្ទៃក្នុង) ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ **E465/4/1.2**, សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ **E465/4/1** កថាខណ្ឌ ៩។

៣២. ដើម្បីអាចផ្តោតលើសារណាបណ្តឹងសាទុក្ខរបស់ខ្លួនបាន មេធាវីការពារក្តីស្នើសុំពន្យារពេលឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ដែលត្រូវដាក់យ៉ាងយូរបំផុត ត្រឹមថ្ងៃទី ២០ ខែសីហា ឆ្នាំ២០១៩[33]។

៣៣. មាត្រា ៨.៣ នៃសេចក្តីណែនាំអនុវត្ត ចែងថា ចម្លើយតបណាមួយទៅនឹងពាក្យសុំ ឬសារណា ត្រូវដាក់ក្នុងរយៈពេល ១០ ថ្ងៃ គិតចាប់ពីពេលជូនដំណឹងអំពីឯកសារដែលភាគីត្រូវឆ្លើយតប។ វិធាន ៣៩(២) និងវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុងផ្តល់នីតិសម្បទាដល់ចៅក្រមក្នុងការពន្យារពេលវេលាកំណត់[34]។

៣៤. យោងតាមយុត្តិសាស្ត្ររបស់តុលាការកំពូល ភាពស្មុគស្មាញនៃបញ្ហាដែលបានលើកឡើង និងបន្ទុកការងារ អាចជាមូលហេតុក្នុងការលើកពេលចាប់ផ្តើមកាលកំណត់សម្រាប់ចម្លើយតប និងការពន្យារពេលវេលាកំណត់[35]។ នៅក្នុងសំណុំរឿង ០០២/០១ តុលាការកំពូលបានឯកភាពតាមសំណើរបស់មេធាវីការពារក្តីទាំងពីរក្រុម ក្នុងការឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីពេលដាក់សារណារបស់ខ្លួន[36]។ តុលាការកំពូលបានពិចារណាទៅលើ "សារៈសំខាន់នៃសារណាបណ្តឹងសាទុក្ខ"[37] និងទទួលស្គាល់ថា ការកំណត់ពេល

---

[33] វិធាន ១០៧(៤) នៃវិធានផ្ទៃក្នុង។

[34] សូមមើលខាងលើ កថាខណ្ឌ ១២។

[35] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំពន្យារពេលដើម្បីធ្វើសារណាតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់ជនជាប់ចោទ នួន ជា តាមវិធាន ១០៤(៤)(ឃ) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ ឯកសារ **E116/1/2/1** កថាខណ្ឌ ៦, សេចក្តីសម្រេចលើសំណើរបស់សហមេធាវីការពារក្តី ខៀវ សំផន សុំពន្យារពេលធ្វើការឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី២០ ខែវិច្ឆកា ឆ្នាំ២០១២ ឯកសារ **E163/5/1/2/1** កថាខណ្ឌ ៧, សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អៀង សារី សុំដាក់បណ្តឹងសាទុក្ខតែជាភាសាអង់គ្លេសសិន ហើយអត្ថបទជាភាសាខ្មែរនឹងដាក់តាមក្រោយ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៣ ឯកសារ **E254/3/1/1.2** កថាខណ្ឌ ៥។

[36] សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំបន្ថែមចំនួនទំព័រដើម្បីប្តឹងសាទុក្ខ និងបន្ថែមពេលវេលាដើម្បីដាក់សារណាតប ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ **F13/2** ("សេចក្តីសម្រេច **F13/2**")។

[37] សេចក្តីសម្រេច **F13/2** កថាខណ្ឌ ១៣។

វេលា នៅក្នុងមាត្រា ៨.៣ នៃសេចក្តីណែនាំអនុវត្ត "នឹងតម្រូវឲ្យ នួន ជា និង ខៀវ សំផន បង្វែរការយកចិត្តទុកដាក់ចេញពីសារណាបណ្តឹងសាទុក្ខរបស់ខ្លួន"[38]។

៣៥. សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ក្នុងសំណុំរឿង ០០២/០២ ប្រកាសអំពីការប្តឹងសាទុក្ខលើបញ្ហាអង្គច្បាប់ និងអង្គហេតុស្មុគស្មាញ និងខុសប្លែកពីគេ ដែលមិនធ្លាប់ត្រូវបានលើកឡើងទាល់តែសោះ នៅចំពោះមុខតុលាការកំពូល (ឬនៅចំពោះមុខតុលាការអន្តរជាតិផ្សេងទៀត)។ ខុសពីបញ្ហាច្បាប់សុទ្ធសាធ ដែលសហព្រះរាជអាជ្ញាបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខលើសំណុំរឿង ០០២/០១ (ភាពអាចអនុវត្តបានចំពោះមុខ អ.វ.ត.ក នូវទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម)[39] បញ្ហាអង្គច្បាប់ និងអង្គហេតុ ដែលសហព្រះរាជអាជ្ញាលើកឡើងនាពេលនេះ (ការរកឃើញឧក្រិដ្ឋកម្ម តាមរយៈអំពើអមនុស្សធម៌ផ្សេងទៀត លើជនរងគ្រោះនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលត្រូវបានបង្ខិតបង្ខំឲ្យរួមភេទ) មិនមែនជាកម្មវត្ថុនៃសេចក្តីសន្និដ្ឋាន និងសេចក្តីសម្រេចជាច្រើន នៅដំណាក់កាលស៊ើបសួរ និងជំនុំជម្រះក្តីនោះទេ។

៣៦. ម្យ៉ាងវិញទៀត ដោយហេតុថា លោក ខៀវ សំផន មិនត្រូវបានផ្តន្ទាទោសពីបទនេះ ច្បាស់ណាស់ថាពេលសរសេរសារណាបណ្តឹងសាទុក្ខ ដែលមានទំហំធំលើសសហព្រះរាជអាជ្ញា មេធាវីការពារក្តីនឹងមិនលើកឡើងអំពីច្បាប់ជាធរមាន និងភស្តុតាងពាក់ព័ន្ធនឹងបញ្ហានេះទេ។

៣៧. ទោះបីជាសហព្រះរាជអាជ្ញាដាក់សារណាបណ្តឹងសាទុក្ខ មុន ឬនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ ក៏ដោយ ក៏មេធាវីការពារក្តីនឹងកំពុងតែសរសេរសារណាបណ្តឹងសាទុក្ខរបស់ខ្លួន ហើយត្រូវផ្តោតលើការសរសេរនោះ។ ដូច្នេះ វាប្រហែលជាមិនអត់ប្រយោជន៍ទេក្នុងការរម្លឹកថា បញ្ហាប្រឈមសម្រាប់លោក ខៀវ សំផន ក្នុងការប្តឹងសាទុក្ខប្រឆាំងនឹងការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោសលើរូបគាត់ មានទំហំធំជាងសហព្រះរាជអាជ្ញាឆ្ងាយណាស់។

៣៨. ហេតុដូច្នេះ មេធាវីការពារក្តីគួរត្រូវអនុញ្ញាតឲ្យដាក់ចម្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ក្នុងរយៈពេល ៤០ ថ្ងៃ គិតចាប់ពីពេលដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន។

---

[38] សេចក្តីសម្រេច **F13/2** កថាខណ្ឌ ១២។

[39] សេចក្តីសម្រេច **F13/2** កថាខណ្ឌ ១១។

## III. **លទ្ធភាពបើកកិច្ចប្រជុំរៀបចំសវនាការ**

៣៩. យោងតាមវិធាន ៧៩(៧) និងវិធាន ១០៤ ស្ទួន នៃវិធានផ្ទៃក្នុង តុលាការកំពូលអាចសម្រេចធ្វើការប្រជុំរៀបចំសវនាការជាអសាធារណៈ ឬជាសាធារណៈ ក្នុងគោលបំណង "អនុញ្ញាតឲ្យមានការផ្លាស់ប្តូរមតិយោបល់គ្នារវាងភាគីទាំងឡាយ ដើម្បីសម្របសម្រួលការកំណត់កាលបរិច្ឆេទនៃការធ្វើសវនាការ (...) និងពិនិត្យឡើងវិញនូវរឿងក្តី ដោយអនុញ្ញាតឲ្យជនជាប់ចោទលើកឡើងនូវបញ្ហាទាំងឡាយទាក់ទងនឹងរឿងក្តីនោះ រួមទាំងស្ថានភាពរូបកាយ និងស្មារតី"។

៤០. ប្រសិនបើតុលាការកំពូលគ្រោងផ្តល់ពេលវេលាតិចជាងការស្នើសុំក្នុងសំណើនេះ តុលាការកំពូលត្រូវគ្រោងបើកកិច្ចប្រជុំរៀបចំសវនាការ ជាសាធារណៈ។ កិច្ចប្រជុំនេះនឹងអាចធ្វើឲ្យនីតិវិធីបណ្តឹងសាទុក្ខមានលក្ខណៈសមរម្យ និងជាក់ស្តែងជាងមុន។ ជាពិសេស តុលាការកំពូលអាចកោះហៅតំណាងមកពីការិយាល័យរដ្ឋបាល និងអង្គភាពបកប្រែភាសា ឲ្យចូលរួមក្នុងកិច្ចប្រជុំនេះផងដែរ។ ករណីនេះអាចជួយឲ្យតុលាការកំពូលដឹងថា មេធាវីការពារក្តីពិតជាជួបប្រទះនឹងឧបសគ្គជាក់ស្តែងប្រាកដមែន ប្រសិនបើតុលាការកំពូលមិនជឿលើការលើកឡើងរបស់មេធាវីការពារក្តី។

៤១. **អាស្រ័យហេតុនេះ** មេធាវីការពារក្តីស្នើសុំតុលាការកំពូលមេត្តា៖
- **អនុញ្ញាត**ឲ្យមេធាវីការពារក្តីដាក់សារណាបណ្តឹងសាទុក្ខកម្រាស់ ៩៥០ ទំព័រ ជាភាសាបារាំងតែមួយជាមុនសិន ក្នុងរយៈពេល ១០,៥ ខែ គិតចាប់ពីពេលដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងដាក់សំណៅបកប្រែជាភាសាខ្មែរតាមក្រោយឲ្យបានឆាប់បំផុត
- **អនុញ្ញាត**ឲ្យមេធាវីការពារក្តីដាក់ចម្លើយតប ទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ក្នុងរយៈពេល ៤០ ថ្ងៃ គិតចាប់ពីពេលដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន
- *ជាសំណើបន្ទាប់បន្សំ* **គ្រោង**បើកកិច្ចប្រជុំរៀបចំសវនាការ ជាសាធារណៈ។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ | រាជធានីភ្នំពេញ<br><br>ទីក្រុងប៉ារីស | |